**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
លេខៈ ០៧៦/២២......អអរ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និង ទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តព្រះវិហារ"

ព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តព្រះវិហារ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ឡុង សុវណ្ណា ប្រធានក្រុមប្រឹក្សាខេត្តព្រះវិហារ**
- **លោក ម៉ាន សារ៉ុម មេឃុំទឹកក្រហម ស្រុកជាំក្សាន្ត**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបំផុស និងបង្ហាញជាសាធារណនូវយន្តការ គណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាប្រវត្តិសាស្ត្រ កម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេច បាន ក្នុងកិច្ចរក្សាបាននូវការជឿទុកចិត្ត ចូលរួម និងគាំទ្រពីប្រជាពលរដ្ឋ តាមយុទ្ធសាស្ត្រកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។**

### I. សេចក្តីផ្តើម

ខេត្តព្រះវិហារ មានផ្ទៃដីសរុបចំនួន ១៣,៨២១,៧៦ គ.ម$^2$ ចែកចេញ ៧ស្រុក ១ក្រុង និង ៤៩ឃុំ ២សង្កាត់ ២៣២ភូមិ មានប្រជាពលរដ្ឋរស់នៅសរុបចំនួន ២៤៨,២៥១ នាក់ ស្រី ១២៤,៥១៣ នាក់។ ក្នុងចំណោមប្រជាជនសរុប មានប្រមាណ ១១.២០ភាគរយជាជនជាតិកួយ។ ប្រជាពលរដ្ឋមានប្រមាណ ៨៥ភាគរយជាកសិករពឹងផ្អែកលើវិស័យកសិកម្ម ដែលជាវិស័យចម្បង។

### II. វឌ្ឍនភាពការងារ

❖ **ក្រុមប្រឹក្សាខេត្ត**



Scanned with CamScanner

- ក្រុមប្រឹក្សាខេត្តមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស, គណៈកម្មាធិការលទ្ធកម្ម, គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ, គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស និងគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។
- បានប្រជុំទៀងទាត់ តាមប្រតិទិនស្ដីពីកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ចំនួន ៣២លើក។
- បានចេញសេចក្ដីសម្រេច ការបែងចែកតួនាទី ភារកិច្ចជូនសមាជិកក្រុមប្រឹក្សាខេត្ត ឱ្យចុះសហការជាមួយរដ្ឋបាលក្រុង ស្រុកក្នុងការប្រមូលរាល់ព័ត៌មាន សំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីរៀបចំជារបាយការណ៍សម្រាប់ដាក់បញ្ចូលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត ដើម្បីដោះស្រាយ និងឆ្លើយតបតម្រូវការប្រជាពលរដ្ឋ។
- បានចូលរួមផ្សព្វផ្សាយ អប់រំណែនាំប្រជាពលរដ្ឋនៅមូលដ្ឋានតាម សារអប់រំណែនាំរបស់ក្រសួងសុខាភិបាលជាប្រចាំ ព្រមទាំងបានឧបត្ថម្ភថវិកា គ្រឿងឧបភោគ បរិភោគដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺនេះទូទាំងខេត្ត។
- បានត្រួតពិនិត្យដំណើរការឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋក្រីក្រ ស្ត្រីមានផ្ទៃពោះ និងកុមារនៅគ្រប់មូលដ្ឋាន តាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់។
- បានត្រួតពិនិត្យការផ្ដល់សេវាជូនប្រជាពលរដ្ឋនៅអង្គភាពច្រកចេញ-ចូលតែមួយរដ្ឋបាលខេត្ត និងនៅការិយាល័យច្រកចេញ ចូលតែមួយ រដ្ឋបាលក្រុង រដ្ឋបាលស្រុក។

❖ **ឃុំទឹកក្រហម ស្រុកជាំក្សាន្ត**

វឌ្ឍនភាពសំខាន់ៗ ដែលក្រុមប្រឹក្សាឃុំសម្រេចបានរួមមាន៖

- បានអនុវត្តនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព, រៀបចំសណ្ដាប់ធ្នាប់, ការពារសន្តិសុខជូនប្រជាពលរដ្ឋ និងមានការដោះស្រាយ សម្របសម្រួលបណ្ដឹងជូនប្រជាពលរដ្ឋ។
- បានបង្ក្រាបបទល្មើស ដូចជា ល្បែងស៊ីសង គ្រឿងញៀន អំពើលួចឆក់ប្លន់ គ្រោះថ្នាក់ចរាចរ។
- បានរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងឃុំរួមមាន ជួសជុលផ្លូវក្រាលគ្រួស ដាក់លូតាមដងផ្លូវ និងប្រឡាយទឹក ជីកអណ្ដូងទឹកស្អាត ជីកស្រះសហគមន៍ ព្រមទាំងបង្កើតឱ្យមានស្ថានីយទឹកបរិសុទ្ធ ដើម្បីតម្រូវការរបស់ប្រជាពលរដ្ឋ។
- បានឧបត្ថម្ភដល់គ្រួសារក្រីក្រ ស្ត្រីមានផ្ទៃពោះ កុមារ ចាស់ជរា និងបានចុះផ្សព្វផ្សាយអំពីសុខភាពអនាម័យជូនប្រជាពលរដ្ឋ។

Scanned with CamScanner

❖ **ឃុំទឹកក្រហម ស្រុកជាំក្សាន្ត**

ក្នុងឆ្នាំ២០២២នេះ រដ្ឋបាលឃុំទឹកក្រហម បានទទួលនូវថវិកាវិភាជពីរដ្ឋាភិបាលចំនួន ៦៤៦,២៨៣,៦២០ រៀល ក្នុងនោះថវិកា ២៧៧,៦០០,០០០រៀល សម្រាប់ដំណើការរដ្ឋបាល និងឧបត្ថម្ភដល់ក្រុមប្រឹក្សាឃុំ និងមន្ត្រីភូមិ ឯថវិកាចំនួន ៣៦៨,៦៨៣,៦២០រៀលទៀត សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន ដែលមានគម្រោង អតិភាពឆ្នាំ២០២២ ដូចខាងក្រោម ៖

- សាងសង់ផ្លូវដីសប្រវែង ៧០០០ម៉ែត្រ ទទឹង ៥,៥០ម៉ែត្រ។
- ដាក់លូមូលដោះទឹក៦កន្លែង ប្រវែង ៦ម៉ែត្រ។
- ជួសជុលផ្លូវក្រាលគ្រួសក្រហមប្រវែង ៥៥០០ម៉ែត្រ។
- ដាក់លូរំដោះទឹកចំនួន ១០កន្លែង។
- សាងសង់ស្ពាន១កន្លែង ប្រវែង ១៥ម៉ែត្រ។
- សម្រាប់ឆ្នាំបន្តបន្ទាប់ នៅតែបន្តកសាងជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដែលរួមមានបណ្តាញផ្លូវ ស្ពានគ្រប់ប្រភេទ មានការស្តារឡើងវិញឱ្យបានឆាប់រហ័ស នូវបណ្តាញផ្លូវលំដែលខូចខាតដោយទឹកជក់ក្នុងឆ្នាំកន្លងមកដើម្បីធានាការធ្វើដំណើរ និងដឹកជញ្ជូនកសិផលរបស់ប្រជាជននៅតាមមូលដ្ឋានទៅកាន់ទីផ្សារ និង កន្លែងដទៃទៀតបានស្រួល និងឆាប់រហ័ស។
- ពង្រឹងការប្រើប្រាស់ផ្លូវ ប្រកបដោយប្រសិទ្ធភាព ទប់ស្កាត់ការផ្ទុកលើសទម្ងន់របស់យានយន្តគ្រប់ប្រភេទ លើផ្លូវដែលគ្រប់គ្រងដោយឃុំ។
- ខិតខំបំផុសប្រជាជន សប្បុរសជន អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា
- បន្តចូលរួមក្នុងដំណើរការអភិវឌ្ឍ និងគ្រប់គ្រងផ្លូវឱ្យកាន់តែមានលក្ខណៈល្អ ប្រសើរឡើង ពិសេសកែលំអជាជំហ៊ានៗ នូវផ្លូវលំពីក្រាលគ្រួសក្រហមទៅជាផ្លូវក្រាលបេតុងអាមេ។
- ជំរុញការចូលរួមពីវិស័យឯកជន ក្នុងការអភិវឌ្ឍ និងថែទាំផ្លូវថ្នល់ព្រមទាំងការផ្តល់សេវាកម្មដឹកជញ្ជូននៅក្នុងស្រុក ទីប្រជុំជន និងឃុំ។
- ជំរុញការផ្សព្វផ្សាយនូវច្បាប់ចរាចរណ៍ផ្លូវគោកឱ្យបានទូលំទូលាយដល់ប្រជាជន អំពីសុវត្ថិភាពនៃការដឹកជញ្ជូន និងពង្រឹងសុវត្ថិភាពចរាចរណ៍។
- ជំរុញការផ្សព្វផ្សាយការធ្វើអនាម័យ ដើម្បីធានាបាននូវសុខមាលភាពល្អ និងបរិស្ថាន ល្អ ក៏ដូចជាលើកកម្ពស់សោភណភាព និងទេសចរណ៍ផងដែរ។
- ធានាឱ្យប្រជាជននៅតាមភូមិនីមួយៗ មានទឹកស្អាតសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ ក្នុងជីវភាពប្រចាំថ្ងៃ តាមរយៈការស្តារ ជីកអណ្តូងនិងការដោះស្រាយទឹកតាមមធ្យោបាយ ផ្សេងៗនៅភូមិដែលខ្វះទឹកប្រើប្រាស់។
- ជំរុញការផ្គត់ផ្គង់ទឹកស្អាត ដែលមានតំលៃសមរម្យ និងប្រើប្រាស់មានអនាម័យ និងផាសុកភាពឱ្យដល់សហគមន៍មូលដ្ឋាន។



Scanned with CamScanner

- បានចុះផ្សព្វផ្សាយអំពីការណែនាំរបស់រាជរដ្ឋាភិបាល សារអប់រំសុខភាពរបស់ក្រសួងសុខាភិបាល ក្នុងការប្រឆាំងនឹងជំងឺកូវីដ-១៩ ព្រមទាំងបានចែកម៉ាស់ជូនប្រជាពលរដ្ឋ។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត និងដើម្បីប្រមូលពត៌មានចំហពីប្រជាពលរដ្ឋ បើមានលក្ខណសម្បត្តិអនុគ្រោះ។
- បន្តចុះគាំទ្រដល់មូលដ្ឋាន ដើម្បីប្រមូលសំណូមពរ និងតម្រូវការរបស់ប្រជាពលរដ្ឋ។
- ជំរុញ និងគាំទ្រការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយ សំដៅបង្កិតសេវារដ្ឋបាលឱ្យបានកាន់តែគៀកជិតប្រជាពលរដ្ឋនៅមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាពតម្លាភាព និងគណនេយ្យភាព។
- បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍន៍ និងការកសាងកម្មវិធីវិនិយោគ ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ឱ្យមានសង្គតិភាព និងការរៀបចំយុទ្ធសាស្ត្រថវិកា ដើម្បីស្របទៅនឹងតម្រូវការការអភិវឌ្ឍន៍។
- បន្តគាំទ្រ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំ របស់រដ្ឋបាលខេត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន។
- បន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា និងជម្រុញដល់គណៈអភិបាល អនុវត្តតួនាទី ភារកិច្ច ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។
- បន្តពង្រឹងនិងគាំទ្រដល់យន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈការិយាល័យប្រជាពលរដ្ឋខេត្ត។
- បន្តពង្រឹងទំនាក់ទំនងរវាងក្រុមប្រឹក្សា គណៈអភិបាល និងមន្ទីរ អង្គភាពនានា ក្នុងការអនុវត្តតួនាទី ភារកិច្ច និងកៀរគរកម្លាំងដើម្បីអភិវឌ្ឍគ្រប់វិស័យក្នុងមូលដ្ឋាន។
- បន្តការគាំទ្រផែនការសកម្មភាព និងថវិកា ផអ៣ សំដៅពង្រឹងសមត្ថភាពដល់រដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់។
- ជំរុញការអនុវត្តនូវគោលការណ៍រដ្ឋបាលឯកភាព និងគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព។
- ក្នុងបរិបទជំងឺកូវីដ ១៩ ក្នុងនាមរដ្ឋបាលខេត្ត នឹងបន្តចូលរួមសកម្មភាពនានាក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ។



Scanned with CamScanner

- លើកទឹកចិត្តផ្នែកឯកជន ក្នុងការវិនិយោគលើវិស័យអគ្គិសនី សំដៅជំរុញការផ្គត់ផ្គង់អគ្គិសនី ដែលមានតំលៃសមរម្យ ផ្អែកលើការអភិវឌ្ឍប្រភពថាមពល ដែលតភ្ជាប់ពីបណ្តាញជាតិដល់មូលដ្ឋានប្រើប្រាស់។

## IV. សម្គាល់

- ខេត្តព្រះវិហារមានដីដែលមានជីជាតិអំណោយផលខាងវិស័យកសិកម្ម ទាំងដំណាំស្រូវ ដំណាំកសិឧស្សាហកម្ម ដំណាំឈើហូបផ្លែ ដែលមិនត្រឹមតែផ្គត់ផ្គង់តម្រូវការក្នុងខេត្តខ្លួនផ្ទាល់ប៉ុណ្ណោះទេ តែក៏អាចផ្គត់ផ្គង់ទៅបណ្តាខេត្តផ្សេងៗទៀតបានដែរ ដែលបានចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច របស់ខេត្តទាំងមូលមានអាត្រាកំណើនគួរកត់សម្គាល់ ។ ជាមួយគ្នានេះ ខេត្តព្រះវិហារ មានក្រុមហ៊ុនស្ករអំពៅមួយធំ ដែលបណ្តាក់ទុនវិនិយោគមកពីប្រទេសចិនលើផ្ទៃដីប្រមាណ ២ម៉ឺនហិកតា ដែលត្រូវបានចាត់ទុកថា ជារោងចក្រមួយដ៏ធំក្នុងតំបន់អាស៊ី។
- ខេត្តព្រះវិហារមានប្រភពធនធានរ៉ែ សំខាន់ៗ ដូចជា មាស ,ដែក ,ស្ពាន់ និងសំណ ។ល។ ដែលពុំទាន់មានលទ្ធភាពទាញយកផលបាននៅឡើយ។ ជាមួយនេះខេត្តក៏មានប្រាសាទបុរាណជាច្រើនកន្លែងក្នុងនោះមាន ០៣ជាសំខាន់ គឺប្រាសាទព្រះវិហារស្ថិតនៅលើកំពូលភ្នំដងរែក ជាប់ព្រំប្រទល់ព្រះរាជាណាចក្រថៃឡង់ដ៏ ប្រាសាទកោះកែរ និងប្រាសាទព្រះខ័នកំពង់ស្វាយ រមណីយដ្ឋានធម្មជាតិ ទឹកជ្រោះព្រះនិម្មិត ជាប់ព្រំដែនប្រទេសឡាវ និងភ្នំត្បែងស្ថិតក្នុងភូមិសាស្ត្រស្រុកត្បែងមានជ័យ ស្រុកសង្គមថ្មីស្រុកគូលែន ។ល។ ដែលមានសក្តានុពលខ្ពស់ខាងវិស័យទេសចរណ៍។ រាជរដ្ឋាភិបាលក៏បាននិងកំពុងសាងសង់ទំនប់អាងទឹករក្សា ក្នុងភូមិសាស្ត្រឃុំរក្សា ស្រុករវៀង និងឃុំពទ្រា ស្រុកជ័យសែនដោយបិទស្ទឹងសែន ដែលមានសមត្ថភាពអាចរក្សាទឹកទុកបានប្រមាណ ២៥៦,៩ លានម៉ែត្រគីប សម្រាប់ផ្គតផ្គង់ទាំងវិស័យកសិកម្ម និងការប្រើប្រាស់សព្វសារពើ។
- ដោយសារខេត្តព្រះវិហារជាតំបន់ភ្នំ សម្បូរដោយធនធានព្រៃឈើ ទន្ទឹមនេះ បទល្មើសព្រៃឈើក៏តែងកើតមានជាញឹកញាប់ដូចគ្នាដែរ ប៉ុន្តែមកទល់ពេលនេះ បញ្ហាទាំងនេះមានការថយចុះគួរឱ្យកត់សម្គាល់ ខណៈអ្នកប្រព្រឹត្តិល្មើស តែងត្រូវបានធ្វើការអប់រំ និងបញ្ជូនទៅតុលាការចាត់ការតាមនីតិវិធីច្បាប់។

ថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២



CS Scanned with CamScanner